**ព័ត៌មានបច្ចុប្បន្នភាពស្តីអំពីការដាក់ពិន្ទុនិងការរំពឹងទុកសម្រាប់សិស្ស**

សូមជំរាបមកដល់មាតាបិតា អាណាព្យាលបាលសិស្ស:

សូមអគុណដល់អ្វីៗទាំងអស់ដែលលោកអ្នកបានធ្វើដើម្បីគាំទ្រការសិក្សារបស់កូនលោកអ្នកនៅក្នុងពេលដែលសាលារៀនបិទទ្វារដោយសារតែការរាតត្បាតនៃវីរុសកូរ៉ូណា។ ចាប់ផ្តើមពីថ្ងៃព្រហស្បតិ៍ ទី២៣ខែមេសាទៅ កម្មវិធីសិក្សានៅផ្ទះ Home Learning Opportunities របស់ក្រសួងអប់រំយើងនឹងមានការកែសម្រួល។ មកទល់នឹងពេលនេះ កិច្ចការសិស្សពុំមានបានដាក់ពិន្ទុទេ។ ចាប់ពីថ្ងៃព្រហស្បតិ៍ទី២៣មេសាទៅ សិស្សនឹងមានទំនួលខុសត្រូវទៅលើកិច្ចការដែលគ្រូដាក់ឱ្យធ្វើនិងការចូលរួម។ ក៏ប៉ុន្តែ យើងដឹងហើយថា សិស្សមិនមែនត្រឹមតែរៀននៅផ្ទះទេ។ ពួកគេរៀននៅផ្ទះនៅក្នុងកាលៈទេសៈដ៏លំបាកមួយសម្រាប់ពួកគេនិងក្រុមគ្រួសារ។ ជាមួយនឹងវិបត្តិរាតត្បាតនៅក្នុងអារម្មណ៍របស់យើង យើងបានកែសម្រួលវិធានការដាក់ពិន្ទុសិស្ស ដូចដែលមានចែងនៅក្នុងឯកសារ **ការរំពឹងទុកសម្រាប់សិស្សនេះ។**

**ជាសង្ខេប:**
ការដាក់ពិន្ទុនេះគឺអនុវត្តតាមទស្សនាវិជ្ជា " មិនធ្វើឱ្យខូចខាត "

- សិស្សសាលាបឋមសិក្សានឹងពុំមានទទួលរបាយការណ៍សមិទ្ធិកម្ម(ក្រដាសរាយពិន្ទុ)សម្រាប់ឆមាសទី២ទេ។
- សិស្សពីថ្នាក់ទី៦ដល់ទី៨នឹងបានទទួលពិន្ទុ ជាប់ឬធ្លាក់
- សិស្សពីថ្នាក់ទី៩ដល់ទី១២នឹងបានទទួលពិន្ទុផ្តាច់ព្រ័ត ក្រេឌិត/គ្មានក្រេឌិត Credit/No Credit

គោលការណ៍ណែនាំសម្រាប់ចំនួនម៉ោងត្រូវរៀនរាល់ថ្ងៃមានភាពខុសគ្នាទៅតាមកំរិតថ្នាក់

- ថ្នាក់អន្តរ-មត្តេយ្យ (TK) និងថ្នាក់មត្តេយ្យ ១ម៉ោងទៅ១ម៉ោងកន្លះ
- ថ្នាក់ទី១ដល់ទី៥ បីម៉ោង
- ថ្នាក់ទី៦ដល់ទី១២ មួយម៉ោងក្នុងមួយមុខវិជ្ជា រាល់ថ្ងៃ (ថ្ងៃសេសនិងថ្ងៃគត់ ឆ្លាស់ថ្ងៃគ្នា) សរុបទៅគឺបីទៅបួនម៉ោងក្នុងមួយថ្ងៃ។

គ្រូបង្រៀននឹងផ្តល់ការបង្ហាត់បង្រៀនពីចម្ងាយដោយវិធី ស្របពេលគ្នា (សិស្សធ្វើកិច្ចការនិងរៀនស្របពេលជាមួយគ្នា) ហើយនិងវិធី មិនស្របពេលគ្នា (សិស្សរៀនឬធ្វើកិច្ចការដោយផ្ទាល់ខ្លួនតាមពេលវេលាខុសៗពីគ្នារបស់ខ្លួន)

បើលោកអ្នកមានសំណួរអ្វីមួយ សូមទាក់ទងសាលារៀនរបស់កូន។ **រកមើលលេខទូរស័ព្ទបណ្តោះអាសន្នរបស់សាលារៀននៅក្នុងពេលសាលារៀនបិទទ្វារដោយចុចលើកន្លែងនេះ។ (insert link here)**

យើងនឹងបន្តផ្តល់ព័ត៌មានបច្ចុប្បន្នភាពអំពីការបិទទ្វារសាលារៀននៅក្នុងគេហទំព័រ **lbschools.net/coronavirus**, ព្រមទាំងធនធានសិក្សានិងការគាំទ្របច្ចេកទេសនៅក្នុងគេហទំព័រការសិក្សានៅផ្ទះ **Home Learning Opportunities** គឺនៅ lbschools.net/HLO.

យើងសូមប្រាថ្នាឱ្យសិស្សនិងក្រុមគ្រួសារឱ្យរក្សាសុខភាពឱ្យបានល្អនៅក្នុងពេលដែលមានវិបត្តិជាសាកលនេះ។

ដោយអំណរគុណដ៏ជ្រាលជ្រៅដល់ការគាំទ្ររបស់លោកអ្នក។

គ្រិស Chris

គ្រិសស្តូហ្វើ ស្តាញហោហ្សើ Christopher J. Steinhauser
អគ្គនាយកនៃសាលារៀន Superintendent of Schools

| ការរំពឹងសម្រាប់សិស្ស | |
|---|---|
| **សិស្សនឹងអាចប្រើប្រាសកម្មវិធីតាមអនឡាញដើម្បីចូលរួមក្នុងកម្មវិធីសិក្សានៅផ្ទះ** | |
| ថ្នាក់ TK-5 | សិស្សរាល់គ្នានឹងប្រើកម្មវិធី Google Classroom ដើម្បីចូលរួមក្នុងកម្មវិធីសិក្សានៅផ្ទះ; សិស្សដែលមិនមានលទ្ធភាពប្រើប្រាសកម្មវិធី Google Classroom អាចទៅយកក្រដាសមេរៀនពីសាលារៀនដែលមានចែកអាហារ។ |
| 6-12 | គ្រូបង្រៀនរាល់គ្នានឹងប្រើ Google Classroom, ហើយបញ្ជាប់ថ្នាក់រៀន Classroom ទៅនឹងប្រព័ន្ធ School Loop ដើម្បីជួយផ្តល់ព័ត៌មានដល់មាតាបិតាអំពីកិច្ចការសម្រាប់សិស្ស។ |
| **ដោយយោងទៅតាមតារាងវេលាខុសៗគ្នាទៅតាមកំរិតថ្នាក់ គ្រូបង្រៀននឹងផ្តល់ការបង្ហាត់បង្រៀនបីទៅបួនម៉ោងក្នុងមួយថ្ងៃតាមវិធីរៀនស្របគ្នា (សិស្សធ្វើកិច្ចការនិងរៀនស្របពេលជាមួយគ្នា) ហើយនិងតាមវិធី មិនស្របពេលគ្នា (សិស្សរៀនឬធ្វើកិច្ចការដោយផ្ទាល់ខ្លួនតាមពេលវេលាខុសៗពីគ្នារបស់ខ្លួន)** | |
| TK-5 | -មួយម៉ោងក្នុងមួយថ្ងៃសិស្សរៀនមុខវិជ្ជាភាសាសិល្ប៍ ដោយវិធីស្របពេលគ្នានិងឬមិនស្របពេលគ្នា(៣០នាទីសម្រាប់ថ្នាក់ TK/K ថ្នាក់មុនចូលមត្តេយ្យនិងថ្នាក់មត្តេយ្យ )<br>-មួយម៉ោងក្នុងមួយថ្ងៃសិស្សរៀនមុខវិជ្ជាគណិតវិទ្យា ដោយវិធីស្របពេលគ្នានិងឬមិនស្របពេលគ្នា(៣០នាទីសម្រាប់ថ្នាក់ TK/K ថ្នាក់មុនចូលមត្តេយ្យនិងថ្នាក់មត្តេយ្យ)<br>-មួយម៉ោងក្នុងមួយថ្ងៃសិស្សរៀនមុខវិជ្ជាវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ កាយវប្បកម្ម សិល្បៈ និងឬភ្លេង (៣០នាទីសម្រាប់ថ្នាក់ TK/K ថ្នាក់មុនចូលមត្តេយ្យនិងថ្នាក់មត្តេយ្យ) |
| 6-12 | -ប្រហែលមួយម៉ោងក្នុងមួយថ្ងៃសិស្សរៀន ដោយវិធីស្របពេលគ្នានិងឬមិនស្របពេលគ្នា (ថ្ងៃសេសនិងថ្ងៃគត់ ឆ្លាស់ថ្ងៃគ្នា)<br>-មេរៀនបន្ថែមអាចត្រូវគ្រូដាក់ឱ្យធ្វើនៅក្នុងពេលផ្ទាល់ខ្លួន |
| **សិស្សនឹងបានទទួលយោបល់ណែនាំពីគ្រូ** | |
| TK-5 | -សិស្សចាំបាច់ត្រូវធ្វើកិច្ចការដែលគ្រូដាក់ឱ្យធ្វើ<br>-គ្រូនឹងផ្តល់យោបល់ណែនាំជាលាយលក្ខណ៍អក្សរនិងដោយមាត់ទៅលើការលូតលាស់របស់សិស្សអំពីជំនាញនិងស្តង់ដា<br>-សម្រាប់ពេលធ្វើរបាយការណ៍ពិន្ទុលើកទី២ ការប្រើប្រាសរបាយការណ៍សមិទ្ធិផល(ក្រដាសរាយពិន្ទុ)និងលក្ខណៈវិនិច្ឆ័យនៃការតម្លើងថ្នាក់/ការដាក់ឱ្យរៀនត្រួតថ្នាក់ នឹងត្រូវផ្អាកមួយរយៈ |
| 6-8 | -សិស្សចាំបាច់ត្រូវធ្វើកិច្ចការដែលគ្រូដាក់ឱ្យធ្វើ<br>-គ្រូនឹងផ្តល់យោបល់ណែនាំជាលាយលក្ខណ៍អក្សរនិងដោយមាត់ទៅលើការលូតលាស់របស់សិស្សអំពីជំនាញនិងស្តង់ដា<br>-ពុំមានផ្តល់ជាពិន្ទុសម្រាប់ត្រីមាសទី៣ឬករបាយការណ៍លូតលាស់វគ្គត្រីមាសទេ<br>-របាយការណ៍ពិន្ទុនឹងមានចេញឱ្យសិស្សសម្រាប់ឆមាសទី២ |

| | |
|---|---|
| | -ការដាក់ពិន្ទុនេះគឺអនុវត្តតាមទស្សនាវិជ្ជា "មិនធ្វើឱ្យខូចខាត" ដោយប្រើពិន្ទុជាប់ឬធ្លាក់សម្រាប់ពិន្ទុផ្តាច់ព្រ័ត ក៏ប៉ុន្តែក៏លើកទឹកចិត្តឱ្យធ្វើកិច្ចការក្នុងកម្មវិធីសិក្សានៅផ្ទះដែរ |
| 9-12 | -សិស្សចាំបាច់ត្រូវធ្វើកិច្ចការដែលគ្រូដាក់ឱ្យធ្វើ<br>-គ្រូនឹងផ្តល់យោបល់ណែនាំជាលាយលក្ខណ៍អក្សរនិងដោយមាត់ទៅលើការលូតលាស់របស់សិស្សអំពីជំនាញនិងស្តង់ដា<br>-ពុំមានផ្តល់ជាពិន្ទុសម្រាប់ត្រីមាសទី៣ឬករបាយការណ៍លូតលាស់វគ្គត្រីមាសទេ<br>-របាយការណ៍ពិន្ទុនឹងមានចេញឱ្យសិស្សសម្រាប់ឆមាសទី២<br>-ការដាក់ពិន្ទុនេះគឺអនុវត្តតាមទស្សនាវិជ្ជា "មិនធ្វើឱ្យខូចខាត" ដោយប្រើពិន្ទុជាប់ឬធ្លាក់សម្រាប់ពិន្ទុផ្តាច់ព្រ័ត ក៏ប៉ុន្តែក៏លើកទឹកចិត្តឱ្យធ្វើកិច្ចការក្នុងកម្មវិធីសិក្សានៅផ្ទះដែរ |